## សេចក្តីថ្លែងការណ៍រួម

## ទិវាសិទ្ធិនារីអន្តរជាតិ ៨ មីនា ឆ្នាំ ២០១៧ ខួបលើកទី ១០៦

ទិវានារីអន្តរជាតិ (៨មិនា) គឺជាទិវាមួយដែលត្រូវបានគេប្រារព្វឡើងដើម្បីរំលឹកដល់ការតស៊ូរបស់ពលករស្ត្រីទូទាំងពិភពលោក ក្នុងការទាមទារសិទ្ធិសេរីភាព ប្រជាធិបតេយ្យ និងទាមទារអោយមានការទទួលស្គាល់ និងអនុវត្តសិទ្ធិស្មើគ្នារវាងនារី និងបុរស។

ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សសំខាន់ៗនានា រួមមានទាំងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (ស៊ីដ) ផងដែរ ដែលធានានូវការការពារសិទ្ធិមនុស្សរបស់ស្ត្រី ។ ប៉ុន្តែយើងបានធ្វើការកត់សម្គាល់ថា ការរំលោភសិទ្ធិស្ត្រីស្ទើរគ្រប់វិស័យនៅតែបន្តកើតមាន ដូចជាការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនយោបាយ និង សិទ្ធិដីធ្លី ។ ការរើសអើងលើស្ត្រីតាមរយៈទម្រង់នៃការប្រើអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាស់ក៏បន្តរកើតមានជាញឹកញាប់ ។ ការរើសអើងលើស្ត្រីកើតមាននៅគ្រប់វិស័យឧស្សាហ៍កម្មនានា ដែលនាំអោយប៉ះពាល់ដល់ស្ត្រីជាកម្មកររោងចក្រ ស្ត្រីធ្វើការតាមផ្ទះ ស្ត្រីបម្រើការនៅតាមសេវាកម្មកម្សាន្ត ស្ត្រីធ្វើការដោយចំណាកស្រុកនៅក្នុងប្រទេស និងក្រៅប្រទេស និងស្ត្រីដែលកំពុងបម្រើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដ៏ទៃទៀត ។

ក្នុងនាមយើងខ្ញុំ ជាតំណាងសហជីព សហគមន៍ សមាគម និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើសក្មភាព ដើម្បីជម្រុញឲ្យមានភាពប្រសើរឡើងនូវការគោរពសិទ្ធិមនុស្សរបស់ស្ត្រី សូមស្នើដោយទទូចដល់រាជរដ្ឋាភិបាល និងស្ថាប័នរដ្ឋដែលពាក់ព័ន្ធមេត្តាចាត់នូវវិធានការដូចខាងក្រោម៖

១) ធានាអោយមានការចូលរួមស្មើភាពគ្នារបស់ស្ត្រីនៅក្នុងការបោះឆ្នោតឃុំ/សង្កាត់ខាងមុខនេះ ដោយជម្រុញអោយមានការដាក់បញ្ជីឈ្មោះឆ្លាស់រវាងបេក្ខជនស្ត្រី និងបុរស ។

២) ចាត់នូវវិធានការដូចខាងក្រោមដើម្បីការពារដល់កម្មករជាស្ត្រី៖

- ធ្វើវិសោធនកម្ម លើច្បាប់សហជីព និងលុបចោលនីតិវិធីការចុះបញ្ជិកាសហជីព ដែលមានចរឹតរឹតត្បិត ដល់ការអនុវត្តន៍សិទ្ធិជាមូលដ្ឋានរបស់កម្មករនិយោជិត ដោយអនុលោមតាម អនុសញ្ញា លេខ ៨៧ និង ៩៨ ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ននៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ១៩៩៩ ។
- កំណត់ប្រាក់ឈ្នួលជាសកល សម្រាប់កម្មករនិយោជិក នៅគ្រប់វិស័យ ។
- ផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៨៣ ស្តីពី " ការការពារស្ត្រីលំហែមាតុភាព" ។
- ផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨៩ ស្តីពី " ការងារសមរម្យសម្រាប់កម្មករធ្វើការងារតាមផ្ទះ " ។
- ផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពី កិច្ចការពារសិទ្ធិរបស់ពលករចំណាកស្រុកសមាជិក និងក្រុមគ្រួសាររបស់អ្នកទាំងនោះ ដែលរដ្ឋាភិបាលបានចុះហត្ថលេខាក្នុងឆ្នាំ ២០០៤ ។

៣) ដោះលែងសកម្មជនសិទ្ធិមនុស្ស ដែលត្រូវបានឃុំខ្លួន ដោយមូលហេតុនៃការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ពួកគាត់ក្នុងការបញ្ចេញមតិ និងធ្វើការជួបជុំ ។

៤) សូមធ្វើវិសោធនកម្មច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលអនុលោមទៅតាមក្របខណ្ឌរបស់អនុសញ្ញាស៊ីដ ។

៥) សូមធានាឲ្យបាននូវឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌ ដោយស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសិទ្ធិសញ្ញាអន្តរជាតិនានា ដើម្បីអោយស្ត្រីទទួលបានយុត្តិធ៌មពេញលេញ ។

៦) បែងចែកការដាក់ទោសទណ្ឌសម្រាប់អ្នកដែលជាជនសង្ស័យប្រកបអាជីវកម្មផ្លូវភេទនៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ។ ការទប់ស្កាត់ការជួញដូរមនុស្ស គួរតែផ្តោតទៅលើតែអ្នកដែលចូលរួមនៅក្នុងការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ មិនមែនអ្នកដែលត្រូវបានគេកេងប្រវ័ញ្ចអោយធ្លាក់ខ្លួនចូលនៅក្នុងឧស្សាហ៍កម្មផ្លូវភេទទេ ។

៧) សូមអនុវត្តអោយបានពេញនូវសេចក្តីសម្រេច លេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដោយការបណ្តុះបណ្តាលដល់កងសន្តិសុខ មន្ត្រីយោធា កងរាជអាវុធហត្ថ នគរបាលជាតិ និងព្រមទាំងអ្នកដែលត្រូវបានជួលឲ្យបំពេញការងារជំនួស ឫសហការណ៍ជាមួយរដ្ឋាភិបាល ស្តីអំពីការដោះស្រាយទំនាស់បែបអហិង្សា ជាពិសេសអំពីរបៀបធ្វើអន្តរកម្មជាមួយនឹងសមាជិកសង្គមស៊ីវិលទាំងអស់ ក្រុមអ្នកតវ៉ាជាស្ត្រី និងកុមារ។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាល និងស្ថាប័នជាតិនានានឹងចាត់វិធានការដាក់លាក់ក្នុងការឆ្លើយតបចំពោះសំណូមពររបស់យើងខ្ញុំ និង ក៏ដូចជាឆ្លើយតបទៅតាមឆន្ទះរបស់រដ្ឋាភិបាលក្នុងការវិនិយោគលើសមភាពយេនឌ័រ ស្របទៅតាមទិសដៅទី០៥ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDG) ដើម្បីជាប្រយោជន៍សម្រាប់ការកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅគ្រប់វិស័យផងដែរ។

ភ្នំពេញ,ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

១.កញ្ញា អ៊ុំ វណ្ណា ០១០ ៨១៤ ១៨៦ អគ្គលេខាធិការបណ្តាញយុវជនកម្ពុជា

២.លោកស្រី ឆន សុខា ០១២ ៦៥០ ០១៣ ប្រធានកម្មវិធីចងក្រងនៃ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនៃសិទ្ធិមនុស្ស

៣.អ្នកស្រី អ៊ូ ទេពផល្លីន ០១១ ៩៨៤ ៨៨៣ អនុប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា

៤. អ្នកស្រី វ៉ុន សម្ផស្ស ០១៧ ៧៣ ៤៤ ៩៨ ប្រធានបណ្តាញកម្មករធ្វើការតាមផ្ទះ

៥.អ្នកស្រី ជឹម ចាន់នាង ០១២ ៦៦៨ ៨៥៣ អគ្គលេខាធិការនៃ NGO-CEDAW